លឹម ផល្គុន និង សែន ពិសិដ្ឋ

បរិញ្ញាបត្រផ្នែកគណិតវិទ្យា

# សិក្សាគណិតវិទ្យាដោយខ្លួនឯង

# ចំនួនកុំផ្លិច

## សម្រាប់ថ្នាក់ទី ១០_១១

## សិស្សពូកែ និង អាហារូបករណ៍

$$(a+i.b)(c+i.d)=(ac-bd)+i.(ad+bc)$$

រក្សាសិទ្ធិ

## អ្នកចូលរួមត្រួតពិនិត្យបច្ចេកទេស

លោក លឹម ឆុន

លោក សែន ពិសិដ្ឋ

លោកស្រី ឆុយ វណ្ណា

លោក ឆិត្យ ម៉េង

លោក ព្រឹម សុនិត្យ

លោក ផល ប៊ុនឆាយ

## អ្នកត្រួតពិនិត្យអក្ខរាវិរុទ្ធ

លោក លឹម មិត្តសិរ

## ការិកុំព្យូទ័រ

កញ្ញា លី គុណ្ណាភា

## អ្នកនិពន្ធ និង រៀបរៀង

លោក លឹម ផល្លុន និង លោក សែន ពិសិដ្ឋ

# ចំនួនកុំផ្លិច

## ១-និយមន័យ

ក. ចំនួននិម្មិត

ផលគុណនៃចំនួនពិត $\mathbf{c}$ ខុសពីសូន្យនឹង $\mathbf{i}$ ហៅថាចំនួននិម្មិត ។

$\mathbf{i}$ ហៅថាឯកតានិម្មិតដែល $\mathbf{i^2 = -1}$ ឬ $\mathbf{i = \sqrt{-1}}$ ។

ឧទាហរណ៍ : $\mathbf{2i, -5i, \frac{2i}{3}, \sqrt{3}i, \ldots}$ ហៅថាចំនួននិម្មិត ។

ខ. និយមន័យចំនួនកុំផ្លិច

ចំនួនកុំផ្លិចជាចំនួនដែលមានរាង $\mathbf{z = a + i.b}$ ដែល $\mathbf{a}$ និង $\mathbf{b}$ ជាចំនួនពិត ។

គេតាងសំណុំនៃចំនួនកុំផ្លិចដោយ $\mathbb{C}$ ។

$\mathbf{a}$ ហៅថាផ្នែកពិតនៃ $\mathbf{z = a + i.b}$ ដែលកំណត់តាងដោយ $\mathbf{Re(z) = a}$ ។

$\mathbf{b}$ ហៅថាផ្នែកនិម្មិតនៃ $\mathbf{z = a + i.b}$ ដែលកំណត់តាងដោយ $\mathbf{Im(z) = b}$ ។

ឧទាហរណ៍១ : $\mathbf{1 + 2i\ ,\ -3 + 2i\ ,\ 4 - 3i\ ,\ -1 - 4i, 5i\ , -7i}$

ហៅថាចំនួនកុំផ្លិច ។

ឧទាហរណ៍២: រកផ្នែកពិត និង ផ្នែកនិម្មិតនៃ $\mathbf{z = 3 + 2i}$ ?

ផ្នែកពិត និង ផ្នែកនិម្មិតនៃ $\mathbf{z = 3 + 2i}$ គឺ $\mathbf{Re(Z) = 3\ ;\ Im(z) = 2}$ ។

## ២-ប្រមាណវិធីលើចំនួនកុំផ្លិច

ក. វិធីបូកចំនួនកុំផ្លិច

ឧបមាថាគេមានពីរចំនួនកុំផ្លិច $z_1 = a + i.b$ និង $z_2 = c + i.d$

ដែល $a, b, c, d$ ជាចំនួនពិត ។

គេបាន $z_1 + z_2 = (a + i.b) + (c + id) = (a + c) + i(b + d)$

ដូចនេះ $z_1 + z_2 = (a + c) + i.(b + d)$ ។

ឧទាហរណ៍ : គេឱ្យចំនួនកុំផ្លិច $z_1 = -3 + 2i$ និង $z_2 = 7 - 5i$ ។

គណនា $z_1 + z_2$

គេបាន $z_1 + z_2 = (-3 + 2i) + (7 - 5i) = (-3 + 7) + (2i - 5i)$

ដូចនេះ $z_1 + z_2 = 4 - 3i$ ។

ខ. វិធីដកចំនួនកុំផ្លិច

ឧបមាថាគេមានពីរចំនួនកុំផ្លិច $z_1 = a + i.b$ និង $z_2 = c + i.d$

ដែល $a, b, c, d$ ជាចំនួនពិត ។

គេបាន $z_1 - z_2 = (a + i.b) - (c + id) = (a - c) + i(b - d)$

ដូចនេះ $z_1 + z_2 = (a - c) + i.(b - d)$ ។

ឧទាហរណ៍ : គេឱ្យចំនួនកុំផ្លិច $z_1 = -3 + 2i$ និង $z_2 = 7 - 5i$ ។

គណនា $z_1 - z_2$

គេបាន $z_1 - z_2 = (-3 + 2i) - (7 - 5i) = (-3 - 7) + (2i + 5i)$

ដូចនេះ $z_1 + z_2 = -10 + 7i$ ។

គ. វិធីគុណចំនួនកុំផ្លិច

ឧបមាថាគេមានពីរចំនួនកុំផ្លិច $z_1 = a + i.b$ និង $z_2 = c + i.d$

ដែល $a, b, c, d$ ជាចំនួនពិត ។

គេបាន $z_1 \times z_2 = (a + i.b)(c + i.d)$

$$= ac + iad + ibc + i^2bd$$

$$= ac + iad + ibc - bd$$

$$= (ac - bd) + i(ad + bc)$$

ដូចនេះ $z_1 \times z_2 = (ac - bd) + i(ad + bc)$ ។

ឧទាហរណ៍ : គេឱ្យចំនួនកុំផ្លិច $z_1 = 2 + i$ និង $z_2 = 1 - 3i$ ។ គណនា $z_1 \times z_2$

គេបាន $z_1.z_2 = (2 + i)(1 - 3i) = 2 - 6i + i - 3i^2 = 5 - 5i$

ដូចនេះ $z_1.z_2 = 5 - 5i$ ។

ឃ. វិធីចែកចំនួនកុំផ្លិច

ឧបមាថាគេមានពីរចំនួនកុំផ្លិច $z_1 = a + i.b$ និង $z_2 = c + i.d$

ដែល $a, b, c, d$ ជាចំនួនពិត ។

គេបាន $\frac{z_1}{z_2} = \frac{a + ib}{c + id} = \frac{(a + ib)(c - id)}{(c + id)(c - id)} = \frac{ac - iad + ibc - i^2bd}{c^2 - i^2d^2}$

$$= \frac{ac - iad + ibc + bd}{c^2 + d^2} = \frac{(ac + bd) + i(bc - ad)}{c^2 + d^2}$$

ដូចនេះ $\frac{z_1}{z_2} = \frac{ac + bd}{c^2 + d^2} + i.\frac{bc - ad}{c^2 + d^2}$ ។

ឧទាហរណ៍ : គេឱ្យចំនួនកុំផ្លិច $z_1 = 1 + 5i$ និង $z_2 = 1 + i$ ។ គណនា $\frac{z_1}{z_2}$

គេបាន $\frac{z_1}{z_2} = \frac{1+5i}{1+i} = \frac{(1+5i)(1-i)}{(1+i)(1-i)} = \frac{1-i+5i+5}{1+1} = \frac{6+4i}{2}$

ដូចនេះ $\frac{z_1}{z_2} = 3 + 2i$ ។

ង. ស្វ័យគុណនៃ **i**

គេមានស្វ័យគុណនៃ **i** ដូចខាងក្រោម :

$i^1 = i$

$i^2 = -1$

$i^3 = i^2.i = -i$

$i^4 = (i^2)^2 = (-1)^2 = 1$

$i^5 = i^4.i = i$

$i^6 = i^5.i = i.i = i^2 = -1$

$i^7 = i^6.i = -i$

$i^8 = i^7.i = -i.i = -i^2 = 1$

— — — — — — — — — — — — — —

— — — — — — — — — — — — — —

ជាទូទៅ $i^{4n} = 1$ , $i^{4n+1} = i$ , $i^{4n+2} = -1$ , $i^{4n+3} = -i$ គ្រប់ $n \in IN$

ដូចនេះចំនួន $i^n$ ស្មើនឹងចំនួនដដែលៗគឺ $i, -1, -i$ និង $1$ គ្រប់ $n \in IN$ ។

ច. ស្វ័យគុណនៃចំនួនកុំផ្លិច

គេមានស្វ័យគុណនៃចំនួនកុំផ្លិចដូចខាងក្រោម :

$$(a+ib)^2 = a^2 - b^2 + i.2ab$$

$$(a+ib)^3 = (a^3 - 3ab^2) + i(3a^2b - b^3)$$

$$(a+ib)^4 = (a^4 - 6a^2b^2 + b^4) + i(4a^3b - 4ab^3)$$

– – – – – – – – – – – – – – – – – – – – – – – – – – –

– – – – – – – – – – – – – – – – – – – – – – – – – – –

$$(a+ib)^n = \sum_{k=0}^{n} C(n,k)\, a^{n-k} b^k . i^k$$

ដែល $c(n,k) = \dfrac{n!}{k!(n-k)!}$ ។

ឧទាហរណ៍ : គណនា $(1+3i)^2$ , $(2+i)^3$ និង $(1+2i)^4$ ។

គេបាន :

$$(1+3i)^2 = 1 + 6i - 9 = -8 + 6i$$

$$(2+i)^3 = 8 + 12i - 6 - i = 2 + 11i$$

$$(1+2i)^4 = 1 + 8i - 24 - 32i + 16 = -7 + 24i$$

ឆ. កុំផ្លិចស្មើគ្នា

ឧបមាថា $z_1 = a + ib$ និង $z_2 = c + i.d$ ដែល $a, b, c, d$ ជាចំនួនពិត ។

$$z_1 = z_2 \Leftrightarrow \begin{cases} a = c \\ b = d \end{cases}$$

ដូចនេះចំនួនកុំផ្លិចពីរស្មើគ្នាលុះត្រាតែផ្នែកពិតស្មើគ្នា និង ផ្នែកនិម្មិតស្មើគ្នា ។

ឧទាហរណ៍ : គេឱ្យ $z_1 = 2 + 3\lambda + 4i\mu$ និង $z_2 = \mu - 9 + 8i$

ចូរកំណត់ពីរចំនួនពិត $\lambda$ និង $\mu$ ដើម្បីឱ្យ $z_1 = z_2$ ?

កំណត់ $\lambda$ និង $\mu$ :

$$2 + 3\lambda + 4i\mu = \mu - 9 + 8i \Leftrightarrow \begin{cases} 2 + 3\lambda = \mu - 9 \\ 4\mu = 8 \end{cases}$$

គេទាញបាន $\mu = 2$ , $\lambda = -3$ ។

ជ. គណនាឬសការេនៃចំនួនកុំផ្លិច

ឧបមាថាគេមានចំនួនកុំផ្លិច $z = a + i.b$ ដែល $a, b$ ជាចំនួនពិត

ដើម្បីគណនាឬសការេនៃ $z$ គេត្រូវអនុវត្តន៏ដូចខាងក្រោម :

តាង $w = x + i.y$ ជាឬសការេនៃ $z = a + i.b$ ( $x, y$ ជាចំនួនពិត)

គេបាន $w^2 = z$

$$(x + i.y)^2 = a + i.b$$

$$(x^2 - y^2) + i(2xy) = a + ib$$

គេទាញបាន $\begin{cases} x^2 - y^2 = a \\ 2xy = b \end{cases}$

ដោះស្រាយប្រពន្ធ័សមីការនេះគេបានគូចម្លើយ $(x, y) = \{(\alpha_1, \beta_1); (\alpha_2, \beta_2)\}$

ដូចនេះ $w_1 = \alpha_1 + i\beta_1$ ; $w_2 = \alpha_2 + i\beta_2$ ។

ឧទាហរណ៍១ : គណនាឬសការេនៃចំនួនកុំផ្លិច $z = 21 + 20i$

តាង $w = x + i.y$ ជាឬសការេនៃ $z = 21 + 20i$ ( $x , y$ ជាចំនួនពិត)

គេបាន $w^2 = z$

$$(x + i.y)^2 = 21 + 20i$$

$$(x^2 - y^2) + i(2xy) = 21 + 20i$$

គេទាញបាន $\begin{cases} x^2 - y^2 = 21 \\ 2xy = 20 \end{cases}$

បន្ទាប់ពីដោះស្រាយប្រពន្ធ័សមីការនេះគេបានគូចម្លើយ :

$x = 5 , y = 2$ ឬ $x = -5 , y = -2$

ដូចនេះ $w_1 = 5 + 2i$ ; $w_2 = -5 - 2i$ ។

ឧទាហរណ៍២ : គណនាឬសការេនៃចំនួនកុំផ្លិច $z = 21 + 20i$

តាង $w = x + i.y$ ជាឬសការេនៃ $z = -8 - 6i$ ( $x , y$ ជាចំនួនពិត)

គេបាន $w^2 = z$

$$(x + i.y)^2 = -8 - 6i$$

$$(x^2 - y^2) + i(2xy) = -8 - 6i$$

គេទាញបាន $\begin{cases} x^2 - y^2 = -8 \\ 2xy = -6 \end{cases}$

បន្ទាប់ពីដោះស្រាយគេបានគូចម្លើយ : $x = 1 , y = -3$ ឬ $x = -1 , y = 3$

ដូចនេះ $w_1 = 1 - 3i$ ; $w_2 = -1 + 3i$ ។

## ៣-ចំនួនកុំផ្លិចឆ្លាស់

ក. និយមន័យ

ចំនួនកុំផ្លិចឆ្លាស់នៃចំនួនកុំផ្លិច $z = a + i.b$ , $a;b \in IR$ គឺជាចំនួនកុំផ្លិចដែល

កំណត់តាងដោយ $\bar{z} = a - i.b$ ។

ឧទាហរណ៍ : ចំនួនកុំផ្លិចឆ្លាស់នៃ $z = 4 + 3i$ គឺ $\bar{z} = 4 - 3i$ ។

ខ. លក្ខណៈ

1. $\overline{(z_1 + z_2)} = \overline{z_1} + \overline{z_2}$
2. $\overline{(z_1 . z_2)} = \overline{z_1} . \overline{z_2}$
3. $\overline{\left(\frac{z_1}{z_2}\right)} = \frac{\overline{z_1}}{\overline{z_2}}$

សម្រាយបញ្ជាក់

តាង $z_1 = a + ib$ និង $z_2 = c + id$ ដែល $a, b, c, d$ ជាចំនួនពិត ។

គេបាន $\overline{z_1} = a - i.b$ និង $\overline{z_2} = c - i.d$

មាន $z_1 + z_2 = (a + c) + i(b + d)$ នោះ $\overline{z_1 + z_2} = (a + c) - i(b + d)$

ហើយ $\overline{z_1} + \overline{z_2} = a - ib + c - id = (a + c) - i(b + d)$

ដូចនេះ $\overline{(z_1 + z_2)} = \overline{z_1} + \overline{z_2}$ ។

គេមាន $z_1 z_2 = (a + ib)(c + id) = (ac - bd) + i(ad + bc)$

គេបាន $\overline{z_1 . z_2} = (ac - bd) - i(ad + bc)$

ហើយ $\overline{z_1} . \overline{z_2} = (a - ib)(c - id) = (ac - id) - i(ad + bc)$

ដូចនេះ $\overline{(z_1.z_2)}=\overline{z_1}.\overline{z_2}$ ។

គេមាន $\frac{z_1}{z_2}=\frac{a+ib}{c+id}=\frac{(a+ib)(c-id)}{(c+id)(c-id)}=\frac{ac+bd}{c^2+d^2}+i.\frac{bc-ad}{c^2+d^2}$

គេបាន $\overline{\left(\frac{z_1}{z_2}\right)}=\frac{ac+bd}{c^2+d^2}-i.\frac{bc-ad}{c^2+d^2}$

ហើយ $\frac{\overline{z_1}}{\overline{z_2}}=\frac{a-ib}{c-id}=\frac{(a-ib)(c+id)}{(c-id)(c+id)}=\frac{ac+bd}{c^2+d^2}-i.\frac{bc-ad}{c^2+d^2}$

ដូចនេះ $\overline{\left(\frac{z_1}{z_2}\right)}=\frac{\overline{z_1}}{\overline{z_2}}$ ។

គ. កន្សោមផ្នែកពិត និង ផ្នែកនិម្មិតជាអនុគមន៍នៃ $z$ និង $\overline{z}$

ឧបមាថាគេមាន $z=a+ib$ នោះ $\overline{z}=a-ib$ ដែល $a;b$ ជាចំនួនពិត ។

គេបាន $z+\overline{z}=a+ib+a-ib=2a$ នោះ $a=\frac{z+\overline{z}}{2}$

ហើយ $z-\overline{z}=a+ib-a+ib=2ib$ នោះ $b=\frac{z-\overline{z}}{2i}$

ដូចនេះ $Re(z)=\frac{z+\overline{z}}{2}$ និង $Im(z)=\frac{z-\overline{z}}{2i}$ ។

-បើ $Re(z)=0$ នោះ $z=-\overline{z}$ នាំឱ្យ $z$ ជាចំនួននិម្មិត ។

-បើ $Im(z)=0$ នោះ $z=\overline{z}$ នាំឱ្យ $z$ ជាចំនួនពិត ។

## ៤-អនុវត្តន៍ចំនួនកុំផ្លិចក្នុងដំណោះស្រាយសមីការដឺក្រេទីពីរ

ឧបមាថាគេមានសមីការដឺក្រេទីពីរ $az^2 + bz + c = 0$

ដែល $a \neq 0$ , $a, b, c$ ជាចំនួនពិត ។

ឌីសគ្រីមីណង់នៃសមីការគឺ $\Delta = b^2 - 4ac$

-បើ $\Delta > 0$ សមីការមានឫសពីផ្សេងគ្នាជាចំនួនពិតគឺ :

$$z_1 = \frac{-b + \sqrt{\Delta}}{2a} \ ; \ z_2 = \frac{-b - \sqrt{\Delta}}{2a}$$

-បើ $\Delta = 0$ សមីការមានឫសឌុបជាចំនួនពិតគឺ $z_1 = z_2 = -\frac{b}{2a}$

-បើ $\Delta < 0$ សមីការមានឫសពីផ្សេងគ្នាជាចំនួនកុំផ្លិចឆ្លាស់គ្នាគឺ :

$$z_1 = \frac{-b + i\sqrt{|\Delta|}}{2a} \ ; \ z_2 = \frac{-b - i\sqrt{|\Delta|}}{2a}$$

ឧទាហរណ៍ :

ដោះស្រាយសមីការ $2z^2 - 6z + 5 = 0$

ឌីសគ្រីមីណង់នៃសមីការ $\Delta = 36 - 40 = -4 = 4i^2$

គេទាញឫស $z_1 = \frac{6 - 2i}{4} = \frac{3}{2} - i.\frac{1}{2}$ ; $z_2 = \frac{6 + 2i}{4} = \frac{3}{2} + i.\frac{1}{2}$

ដូចនេះសមីការមានឫសពីរផ្សេងគ្នាជាចំនួនកុំផ្លិចឆ្លាស់គ្នាគឺ :

$z_1 = \frac{3}{2} - i.\frac{1}{2}$ ; $z_2 = \frac{3}{2} + i.\frac{1}{2}$ ។

## ៥.ចំនួនកុំផ្លិចក្នុងប្លង់

ក. ការតាងចំនួនកុំផ្លិចក្នុងប្លង់

ក្នុងតម្រុយអរតូណរមេ **(xoy)** គេអាចតាងចំនួនកុំផ្លិច $\mathbf{z = a + i.b \ ; \ a, b \in IR}$

ដោយចំណុច **M** មួយមានកូអរដោនេ **(a,b)** ។

គេថា **M** ជាចំនុចរូបភាពនៃចំនួនកុំផ្លិច $\mathbf{z = a + ib}$ ហើយ **z** ហៅថាអាភិចនៃ

ចំនុច **M(a,b)** ដែលគេកំណត់សរសេរ **M(z)** ។

ដូចគ្នាដែរ គេក៏អាចតាងចំនួនកុំផ្លិច $\mathbf{z = a + i.b \ ; \ a, b \in IR}$ ដោយវ៉ិចទ័រ

$\overrightarrow{\mathbf{u}} = \overrightarrow{\mathbf{OM}} = \mathbf{(a,b)}$ ។

គេថា $\overrightarrow{\mathbf{u}}$ ជាវ៉ិចទ័ររូបភាពនៃចំនួនកុំផ្លិច $\mathbf{z = a + ib}$ ហើយ **z** ហៅថាអាភិចនៃ

វ៉ិចទ័រ $\overrightarrow{\mathbf{u}}$ ដែលគេកំណត់សរសេរ $\overrightarrow{\mathbf{u}}\mathbf{(z)}$ ។



ខ. វ៉ិចទ័ររូបភាពនៃផលបូកចំនួនកុំផ្លិចក្នុងប្លង់កុំផ្លិច

ក្នុងតម្រុយអរតូណរមេ **(xoy)** ឧបមាថាគេមានចំនួនកុំផ្លិចពីរ $z_1$ និង $z_2$ ហើយតាង $M_1$ និង $M_2$ ជារូបភាពនៃ $z_1$ និង $z_2$ ។

គេបាន $\overrightarrow{OM_1}$ និង $\overrightarrow{OM_2}$ ជាវ៉ិចទ័ររូបភាពនៃ $z_1$ និង $z_2$ ។




គេមាន $z_1 + z_2 = \overrightarrow{OM_1} + \overrightarrow{OM_2} = \overrightarrow{OM}$

ដូចនេះរូបភាពនៃ $z_1 + z_2$ គឺជាវ៉ិចទ័រអង្កត់ទ្រូងនៃប្រលេឡូក្រាម $OM_1MM_2$ ។

គ. វ៉ិចទ័ររូបភាពនៃផលដកចំនួនកុំផ្លិចក្នុងប្លង់កុំផ្លិច

ក្នុងតម្រុយអរតូណរមេ (xoy) ឧបមាថាគេមានចំនួនកុំផ្លិចពីរ $z_1$ និង $z_2$ ហើយតាង $M_1$ និង $M_2$ ជារូបភាពនៃ $z_1$ និង $z_2$ ។

គេបាន $\overrightarrow{OM_1}$ និង $\overrightarrow{OM_2}$ ជាវ៉ិចទ័ររូបភាពនៃ $z_1$ និង $z_2$ ។




គេបាន $z_1 - z_2 = z_1 + (-z_2) = \overrightarrow{OM_1} + \overrightarrow{OM'_2} = \overrightarrow{OM}$

ដូចនេះ រូបភាពនៃ $z_1 - z_2$ គឺជាវ៉ិចទ័រអង្កត់ទ្រូងនៃប្រលេឡូក្រាម $OM_1MM'_2$ ។

ឃ. វិចទ័ររូបភាពនៃផលគុណចំនួនពិត នឹង ចំនួនកុំផ្លិចក្នុងប្លង់កុំផ្លិច :




ឧបមាថា $\mathbf{M}$ និង $\mathbf{M'}$ ជាចំនុចរូបភាពនៃ $\mathbf{z}$ និង $\boldsymbol{\lambda z}$ , $(\lambda > 0)$

រូបភាពនៃ $\lambda.z$ គឺ $\overrightarrow{OM'}$ ដែល $\overrightarrow{OM'} = \lambda\,\overrightarrow{OM}$ ។

## ៦-ម៉ូឌុលនៃចំនួនកុំផ្លិច

ក. និយមន័យ

ក្នុងតម្រុយអរតូណរមេ $(\mathbf{xoy})$ គេយក $\mathbf{M(a,b)}$ ជារូបភាពនៃ $\mathbf{z = a + ib}$ ។

រង្វាស់ $\mathbf{OM}$ ហៅថាម៉ូឌុលនៃ $\mathbf{z = a + ib}$ ។

គេកំណត់តាងម៉ូឌុលនៃ $\mathbf{z = a + ib}$ ដោយ $|\mathbf{z}|$ ឬ $\mathbf{r}$ ដែលអាចគណនាបានតាម

រូបមន្ត $|z| = r = OM = \sqrt{a^2 + b^2}$ ។




ក្នុងត្រីកោណកែង $\mathbf{OMP}$ គេមាន $\mathbf{OM^2 = MP^2 + OP^2}$

ដោយ $\mathbf{OP = a}$ , $\mathbf{MP = b}$

គេបាន $\mathbf{OM^2 = a^2 + b^2}$ ឬ $\mathbf{OM = \sqrt{a^2 + b^2}}$ ។

ដូចនេះ $\mathbf{|z| = OM = \sqrt{a^2 + b^2}}$ ។

ខ. លក្ខណៈ

1. $\mathbf{|z| = |\bar{z}|}$

2. $\mathbf{z.\bar{z} = |z|^2}$

3. $\mathbf{|z_1.z_2| = |z_1|.|z_2|}$

4. $\mathbf{\left|\frac{z_1}{z_2}\right| = \frac{|z_1|}{|z_2|}}$

5. $\mathbf{|z^n| = |z|^n}$

គ. វិសមភាពត្រីកោណ

គ្រប់ចំនួនកុំផ្លិច $z_1$ និង $z_2$ គេមាន $|z_1 + z_2| \le |z_1| + |z_2|$

សម្រាយ :

តាង $z_1 = x + iy$ និង $z_2 = u + iv$

គេមាន $z_1 + z_2 = (x + u) + i(y + v)$

គេបាន $|z_1 + z_2| = \sqrt{(x + u)^2 + (y + v)^2}$

និង $|z_1| + |z_2| = \sqrt{x^2 + y^2} + \sqrt{u^2 + v^2}$

ដោយ $|z_1 + z_2|^2 = x^2 + y^2 + u^2 + v^2 + 2(xu + yv)$

និង $(|z_1| + |z_2|)^2 = x^2 + y^2 + u^2 + v^2 + 2\sqrt{(x^2 + y^2)(u^2 + v^2)}$

គេបាន :

$$(|z_1| + |z_2|)^2 - |z_1 + z_2|^2 = 2\left[\sqrt{(x^2 + y^2)(u^2 + v^2)} - (xu + yv)\right]$$

កន្សោម $(|z_1| + |z_2|)^2 - |z_1 + z_2|^2 \ge 0$ លុះត្រាតែ

$$(x^2 + y^2)(u^2 + v^2) - (xu + yv)^2 \ge 0$$

$$x^2u^2 + x^2v^2 + u^2y^2 + v^2y^2 - x^2u^2 - 2xyuv - y^2v^2 \ge 0$$

$$x^2v^2 - 2xyuv + u^2y^2 \ge 0$$

$$(xv - uy)^2 \ge 0 \text{ ពិត}$$

ដូចនេះ $|z_1 + z_2| \le |z_1| + |z_2|$ ។

## ៧_អាគុយម៉ង់នៃចំនួនកុំផ្លិច

ក្នុងតម្រុយអរតូណរមេ $(xoy)$ គេយក $\mathbf{M(a,b)}$ ជារូបភាពនៃ $\mathbf{z = a + ib}$ ។




មុំដែលផ្គុំដោយ $(\overrightarrow{Ox}, \overrightarrow{OM})$ ហៅថាអាគុយម៉ង់នៃ $\mathbf{z = a + i.b}$ ។

គេតាង $\varphi$ ឬ $\mathbf{Arg(z)}$ ជាអាគុយម៉ង់នៃ $\mathbf{z = a + i.b}$ ។

ក្នុងត្រីកោណកែង $\mathbf{OMP}$ គេមាន :

$\mathbf{r^2 = OM^2 = a^2 + b^2}$ ឬ $\mathbf{r = \sqrt{a^2 + b^2}}$ (ទ្រឹស្តីបទពីតាគ័រ)

$\mathbf{\cos\varphi = \frac{OP}{OM} = \frac{a}{r}}$ និង $\mathbf{\sin\varphi = \frac{MP}{OM} = \frac{b}{r}}$ ។

ដើម្បីរកអាគុយម៉ង់នៃ $\mathbf{z = a + i.b}$ គេដោះស្រាយសមីការ :

$\mathbf{\cos\varphi = \frac{a}{r}}$ និង $\mathbf{\sin\varphi = \frac{b}{r}}$ គេបាន $\mathbf{Arg(z) = \varphi + 2k\pi \; , \; k \in Z}$ ។

ឧទាហរណ៏ ១ : រកអាគុយម៉ង់នៃចំនួនកុំផ្លិច $z = 2\sqrt{3} + 2i$

តាមរូបមន្ត $r = |z| = \sqrt{a^2 + b^2} = \sqrt{(2\sqrt{3})^2 + 2^2} = 4$

$$\cos\varphi = \frac{a}{r} = \frac{2\sqrt{3}}{4} = \frac{\sqrt{3}}{2}$$ និង $$\sin\varphi = \frac{b}{r} = \frac{2}{4} = \frac{1}{2}$$

ដូចនេះអាគុយម៉ង់នៃ $z$ គឺ $\text{Arg}(z) = \frac{\pi}{6} + 2k\pi \; ; k \in Z$

ឧទាហរណ៏ ២ : រកអាគុយម៉ង់នៃចំនួនកុំផ្លិច $z = -1 + i\sqrt{3}$

តាមរូបមន្ត $r = |z| = \sqrt{a^2 + b^2} = \sqrt{(-1)^2 + (3)^2} = 2$

$$\cos\varphi = \frac{a}{r} = -\frac{1}{2}$$ និង $$\sin\varphi = \frac{b}{r} = \frac{\sqrt{3}}{2}$$

ដូចនេះអាគុយម៉ង់នៃ $z$ គឺ $\text{Arg}(z) = \frac{2\pi}{3} + 2k\pi \; ; k \in Z$

ទាហរណ៏ ៣ : រកអាគុយម៉ង់នៃចំនួនកុំផ្លិច $z = \sqrt{2} - i\sqrt{2}$

តាមរូបមន្ត $r = |z| = \sqrt{a^2 + b^2} = \sqrt{2 + 2} = 2$

$$\cos\varphi = \frac{a}{r} = \frac{\sqrt{2}}{2}$$ និង $$\sin\varphi = \frac{b}{r} = -\frac{\sqrt{2}}{2}$$

ដូចនេះអាគុយម៉ង់នៃ $z$ គឺ $\text{Arg}(z) = -\frac{\pi}{4} + 2k\pi \; ; k \in Z$

## ៨_ទម្រង់ត្រីកោណមាត្រនៃចំនួនកុំផ្លិច

ចំនួនកុំផ្លិច $\mathbf{z = a + i.b}$ ហៅថាទម្រង់ពីជគណិត ។ គេអាចសរសេរទម្រង់ថ្មីមួយទៀតដូចខាងក្រោម :

គេមាន $\mathbf{r = \sqrt{a^2 + b^2}}$ ហៅថាម៉ូឌុលនៃ $\mathbf{z = a + i.b}$

$\mathbf{\cos\varphi = \frac{a}{r}}$ និង $\mathbf{\sin\varphi = \frac{b}{r}}$ ដែល $\varphi$ ហៅថាអាគុយម៉ង់នៃ $\mathbf{z}$ ។

គេបាន $\mathbf{z = a + i.b = r(\frac{a}{r} + i.\frac{b}{r}) = r(\cos\varphi + i.\sin\varphi)}$

ដូចនេះ $\mathbf{z = r(\cos\varphi + i.\sin\varphi)}$ ហៅថាទម្រង់ត្រីកោណមាត្រនៃ $\mathbf{z}$ ។

ឧទាហរណ៍ ១ : ចូរសរសេរ $\mathbf{z = 1 + i\sqrt{3}}$ ជារាងត្រីកោណមាត្រ ។

គេមាន $\mathbf{r = \sqrt{1^2 + (\sqrt{3})^2} = 2}$

គេបាន $\mathbf{z = 2(\frac{1}{2} + i.\frac{\sqrt{3}}{2}) = 2(\cos\frac{\pi}{3} + i.\sin\frac{\pi}{3})}$ ។

ឧទាហរណ៍ ២ : ចូរសរសេរ $\mathbf{z = -2\sqrt{3} + 2i}$ ជារាងត្រីកោណមាត្រ ។

គេមាន $\mathbf{r = \sqrt{(-2\sqrt{3})^2 + (2)^2} = 4}$

គេបាន $\mathbf{z = 4(-\frac{\sqrt{3}}{2} + i.\frac{1}{2}) = 4(-\cos\frac{\pi}{6} + i.\sin\frac{\pi}{6})}$ ។

$$\mathbf{z = 4[\cos(\pi - \frac{\pi}{6}) + i.\sin(\pi - \frac{\pi}{6})]}$$

$$\mathbf{z = 4(\cos\frac{5\pi}{6} + i\sin\frac{5\pi}{6})}$$

## ៩_ប្រមាណវិធីលើចំនួនកុំផ្លិចតាមទម្រង់ត្រីកោណមាត្រ

ក. ផលគុណចំនួនកុំផ្លិចតាមទម្រង់ត្រីកោណមាត្រ

ទ្រឹស្តីបទ :

ឧបមាថាគេមានចំនួនកុំផ្លិច $z_1 = r_1(\cos\alpha + i.\sin\alpha)$

និង $z_2 = r_2(\cos\beta + i\sin\beta)$ ដែល $r_1 > 0$ , $r_2 > 0$

គេបាន $z_1.z_2 = r_1 r_2[\cos(\alpha+\beta) + i\sin(\alpha+\beta)]$ ។

សម្រាយបញ្ជាក់

គេបាន $z_1 z_2 = r_1(\cos\alpha + i.\sin\alpha).r_2(\cos\beta + i\sin\beta)$

$$z_1 z_2 = r_1 r_2[(\cos\alpha\cos\beta - \sin\alpha\sin\beta) + i(\sin\alpha\cos\beta + \sin\beta\cos\alpha)$$

ដូចនេះ $z_1.z_2 = r_1 r_2[\cos(\alpha+\beta) + i\sin(\alpha+\beta)]$ ។

ឧទាហរណ៍

គេឱ្យចំនួនកុំឱ្យផ្លិច

$z_1 = 2(\cos\frac{\pi}{5} + i\sin\frac{\pi}{5})$ និង $z_2 = 3(\cos\frac{2\pi}{15} + i\sin\frac{2\pi}{15})$

គណនា $z_1.z_2$

គេបាន $z_1 z_2 = 6[\cos(\frac{\pi}{5} + \frac{2\pi}{15}) + i\sin(\frac{\pi}{5} + \frac{2\pi}{15})]$

$$= 6(\cos\frac{5\pi}{15} + i\sin\frac{5\pi}{15}) = 6(\cos\frac{\pi}{3} + i.\sin\frac{\pi}{3})$$

ដូចនេះ $z_1 z_2 = 6(\cos\frac{\pi}{3} + i.\sin\frac{\pi}{3})$ ។

ខ. ផលគុណចែកចំនួនកុំផ្លិចតាមទម្រង់ត្រីកោណមាត្រ

ទ្រឹស្តីបទ :

ឧបមាថាគេមានចំនួនកុំផ្លិច $\mathbf{z_1 = r_1(\cos\alpha + i.\sin\alpha)}$

និង $\mathbf{z_2 = r_2(\cos\beta + i\sin\beta)}$ ដែល $\mathbf{r_1 > 0}$ , $\mathbf{r_2 > 0}$

គេបាន $\mathbf{\dfrac{z_1}{z_2} = \dfrac{r_1}{r_2}[\cos(\alpha-\beta) + i\sin(\alpha-\beta)]}$ ។

សម្រាយបញ្ជាក់

គេបាន $\dfrac{z_1}{z_2} = \dfrac{r_1}{r_2}.\dfrac{\cos\alpha + i\sin\alpha}{\cos\beta + i\sin\beta}$

$$= \frac{r_1}{r_2}.\frac{(\cos\alpha + i.\sin\alpha)(\cos\beta - i\sin\beta)}{(\cos\beta + i\sin\beta)(\cos\beta - i\sin\beta)}$$

$$= \frac{r_1}{r_2}.\frac{(\cos\alpha\cos\beta + \sin\alpha\sin\beta) + i(\sin\alpha\cos\beta - \sin\beta\cos\alpha)}{\cos^2\beta + \sin^2\beta}$$

$$= \frac{r_1}{r_2}\left[\cos(\alpha-\beta) + i\sin(\alpha-\beta)\right]$$

ដូចនេះ $\mathbf{\dfrac{z_1}{z_2} = \dfrac{r_1}{r_2}[\cos(\alpha-\beta) + i\sin(\alpha-\beta)]}$ ។

គ. ស្វ័យគុណទី $\mathbf{n}$ នៃចំនួនកុំផ្លិចតាមទម្រង់ត្រីកោណមាត្រ :

ទ្រឹស្តីបទ : គ្រប់ចំនួនពិត $\boldsymbol{\varphi}$ និង $\mathbf{r > 0}$ គេបាន :

$$\mathbf{z^n = [r(\cos\varphi + i.\sin\varphi)]^n = r^n(\cos n\varphi + i.\sin n\varphi)}$$

ដែល $\mathbf{n}$ ជាចំនួនគត់រឺឡាទីហ្វ ។

សម្រាយបញ្ជាក់ :

រាមរូបមន្ត $z_1.z_2 = r_1r_2[\cos(\alpha+\beta)+i\sin(\alpha+\beta)]$

គេបានជាបន្តបន្ទាប់ដូចខាងក្រោម :

$$z^2 = z.z = r.r[\cos(\varphi+\varphi)+i\sin(\varphi+\varphi)] = r^2(\cos 2\varphi + i\sin 2\varphi)$$

$$z^3 = z^2.z = r^2.r[\cos(2\varphi+\varphi)+i\sin(2\varphi+\varphi)]$$

$$= r^3(\cos 3\varphi + i.\sin 3\varphi)$$

-----------------------------------

-----------------------------------

ឧបមាថា $z^n = r^n(\cos n\varphi + i.\sin n\varphi)$ ពិត

គេបាន $z^{n+1} = z^n.z = r^n.r[\cos(n\varphi+\varphi)+i\sin(n\varphi+\varphi)]$

$$= r^{n+1}[\cos(n+1)\varphi + i\sin(n+1)\varphi]$$ ពិត

ដូចនេះ $z^n = r^n(\cos n\varphi + i.\sin n\varphi)$ ។

ឃ. រូបមន្តដឺម័រ

គេមាន $z^n = [r(\cos\varphi + i.\sin\varphi)]^n = r^n(\cos n\varphi + i.\sin n\varphi)$

គេបាន $r^n(\cos\varphi + i.\sin\varphi)^n = r^n(\cos n\varphi + i.\sin n\varphi)$

ដូចនេះ $(\cos\varphi + i.\sin\varphi)^n = \cos n\varphi + i.\sin n\varphi$

( ហៅថារូបមន្តដឺម័រ ) ។

ឧទាហរណ៍ : គេឱ្យចំនួនកុំផ្លិច $z=\cos\frac{4\pi}{9}+i.\sin\frac{4\pi}{9}$

ចូរសរសេរ $w=\frac{z^2}{1+z^3}$ ជារាងត្រីកោណមាត្រ ។

តាមរូបមន្តដឺម័រគេមាន $z^2=(\cos\frac{4\pi}{9}+i\sin\frac{4\pi}{9})^2=\cos\frac{8\pi}{9}+i\sin\frac{8\pi}{9}$

និង $z^3=(\cos\frac{4\pi}{9}+i\sin\frac{4\pi}{9})^3=\cos\frac{4\pi}{3}+i\sin\frac{4\pi}{3}$

គេបាន $w=\dfrac{\cos\frac{8\pi}{9}+i.\sin\frac{8\pi}{9}}{1+\cos\frac{4\pi}{3}+i.\sin\frac{4\pi}{3}}$

$$=\dfrac{\cos\frac{8\pi}{9}+i.\sin\frac{8\pi}{9}}{2\cos^2\frac{2\pi}{3}+2i\sin\frac{2\pi}{3}\cos\frac{2\pi}{3}}$$

$$=\frac{1}{2\cos\frac{2\pi}{3}}.\dfrac{\cos\frac{8\pi}{9}+i.\sin\frac{8\pi}{9}}{\cos\frac{2\pi}{3}+i\sin\frac{2\pi}{3}}$$

$$=-[\cos(\frac{8\pi}{9}-\frac{2\pi}{3})+i\sin(\frac{8\pi}{9}-\frac{2\pi}{3})]$$

$$=-(\cos\frac{2\pi}{9}+i\sin\frac{2\pi}{9})=\cos\frac{11\pi}{9}+i\sin\frac{11\pi}{9}$$

ដូចនេះ $w=\cos\frac{11\pi}{9}+i.\sin\frac{11\pi}{9}$ ។

## ១០~បំលែងវិលជុំវិញគល់តម្រុយនៃប្លង់កុំផ្លិច

គេមានចំនួនកុំផ្លិច $\mathbf{w = \cos\psi + i.\sin\psi}$ ។

បើ $\mathbf{M'(z')}$ ជារូបភាពនៃ $\mathbf{M(z)}$ តាមបម្លែងវិលផ្ចិត $\mathbf{O}$ និង មុំ $\psi$ នោះ

គេបាន $\mathbf{z' = w.z = (\cos\psi + i\sin\psi).z}$ ។




ឧទាហរណ៍ ១ : នៅក្នុងប្លង់កុំផ្លិច $\mathbf{(xoy)}$ គេឱ្យ $\mathbf{M}$ ជាចំនុចរូបភាពនៃ $\mathbf{z = \sqrt{3} + i}$ ។

ចូរកំណត់ $\mathbf{z'}$ ដោយដឹងថា $\mathbf{M'(z')}$ ជារូបភាពនៃ $\mathbf{M}$ តាមបម្លែងវិលផ្ចិត $\mathbf{O}$

និងមុំ $\psi = \dfrac{\pi}{12}$ ។

បើ $M'(z')$ ជារូបភាពនៃ $M(z)$ តាមបម្លែងវិលផ្ចិត $O$ និងមុំ $\psi = \frac{\pi}{12}$ នោះគេបាន

$z' = (\cos\frac{\pi}{12} + i\sin\frac{\pi}{12})z$

ដោយ $z = \sqrt{3} + i = 2(\frac{\sqrt{3}}{2} + i.\frac{1}{2}) = 2(\cos\frac{\pi}{6} + i.\sin\frac{\pi}{6})$

គេបាន $z' = 2[\cos(\frac{\pi}{12} + \frac{\pi}{6}) + i\sin(\frac{\pi}{12} + \frac{\pi}{6})]$

ដូចនេះ $z' = 2(\cos\frac{\pi}{4} + i\sin\frac{\pi}{4})$ ។

ឧទាហរណ៍ ២ : នៅក្នុងប្លង់កុំផ្លិច $(xoy)$ គេឱ្យ $M$ ជាចំនុចរូបភាពនៃ $z = 1 - i\sqrt{3}$ ។

ចូរកំណត់ $z'$ ដោយដឹងថា $M'(z')$ ជារូបភាពនៃ $M$ តាមបម្លែងវិលផ្ចិត $O$

និងមុំ $\psi = \frac{2\pi}{3}$ ។

បើ $M'(z')$ ជារូបភាពនៃ $M(z)$ តាមបម្លែងវិលផ្ចិត $O$ និងមុំ $\psi = \frac{2\pi}{3}$ នោះគេបាន

$z' = (\cos\frac{2\pi}{3} + i\sin\frac{2\pi}{3})z$

ដោយ $z = 1 - i\sqrt{3} = 2(\frac{1}{2} - i.\frac{\sqrt{3}}{2}) = 2[\cos(-\frac{\pi}{3}) + i.\sin(-\frac{\pi}{3})]$

គេបាន $z' = 2[\cos(\frac{2\pi}{3} - \frac{\pi}{3}) + i\sin(\frac{2\pi}{3} - \frac{\pi}{3})]$

ដូចនេះ $z' = 2(\cos\frac{\pi}{3} + i\sin\frac{\pi}{3})$ ។

## ១១-ឬសទី n នៃចំនួនកុំផ្លិចតាមទម្រង់ត្រីកោណមាត្រ

ឧបមាថាគេមានចំនួនកុំផ្លិច $z = r(\cos\psi + i\sin\psi)$

តាង $w = \rho(\cos\varphi + i\sin\varphi)$ ជាឬសទី $n$ នៃ $z$ នោះ $w^n = z$

គេបាន $\rho^n(\cos n\varphi + i\sin n\varphi) = r(\cos\psi + i\sin\psi)$

គេទាញ $\begin{cases} \rho^n = r \\ \cos(n\varphi) = \cos\psi \\ \sin(n\varphi) = \sin\psi \end{cases}$ នាំឱ្យ $\begin{cases} \rho = \sqrt[n]{r} \\ \varphi = \dfrac{\psi + 2k\pi}{n} \end{cases}$

ដូចនេះឬសទី $n$ នៃ $z$ កំណត់ដោយ :

$$w_k = \sqrt[n]{r}\left[\cos\left(\frac{\psi + 2k\pi}{n}\right) + i.\sin\left(\frac{\psi + 2k\pi}{n}\right)\right]$$

ដែល $k = 0, 1, 2, ...., n-1$ ។

ឧទាហរណ៍ : គណនាឬសទីបីនៃ $z = 4\sqrt{2} + i.4\sqrt{2}$

គេមាន $z = 4\sqrt{2} + i.4\sqrt{2} = 8(\frac{\sqrt{2}}{2} + i\frac{\sqrt{2}}{2}) = 8(\cos\frac{\pi}{4} + i\sin\frac{\pi}{4})$

គេទាញ $r = 8$ , $\psi = \frac{\pi}{4}$ ។ តាមរូបមន្តឬសទី 3 នៃ $z$ កំណត់ដោយ :

$$w_k = 2\left[\cos\left(\frac{\pi + 8k\pi}{12}\right) + i\sin\left(\frac{\pi + 8k\pi}{12}\right)\right], k = 0, 1, 2$$ ។

ដូចនេះ $w_0 = 2(\cos\frac{\pi}{12} + i\sin\frac{\pi}{12}); w_1 = 2(\cos\frac{3\pi}{4} + i\sin\frac{3\pi}{4})$

និង $w_2 = 2(\cos\frac{17\pi}{12} + i\sin\frac{17\pi}{12})$ ។

## ១២_ទម្រង់អ៊ិចស្ប៉ូណង់ស្យែលនៃចំនួនកុំផ្លិច

ក. រូបមន្តអឺលែ (Euler's formula)

ចំពោះគ្រប់ចំនួនពិត $\mathbf{x}$ គេបាន $\mathbf{e^{ix} = \cos x + i\sin x}$

ដែល $\mathbf{e = 2.71828...}$ ជាគោលលោការីតនេពែ ។

រូបមន្តអឺលែនេះនៅតែពិតចំពោះ $\mathbf{x}$ ជាចំនួនកុំផ្លិចក៏ដោយ ។

សម្រាយបញ្ជាក់

-ស្រាយបញ្ជាក់ដោយប្រើដេរីវេ :

តាងអនុគមន៍ $\mathbf{f}$ ( អាចជាអនុគមន៍កុំផ្លិច) នៃអថេរ $\mathbf{x}$ កំណត់ដោយ

$$f(x) = \frac{\cos x + i\sin x}{e^{ix}}$$

គេបាន $$f'(x) = \frac{(-\sin x + i\cos x)e^{ix} - ie^{ix}(\cos x + i\sin x)}{e^{2ix}}$$

$$= \frac{e^{ix}(-\sin x + i\cos x - i\cos x - i^2\sin x)}{e^{2ix}}$$

$$= \frac{-\sin x + i\cos x - i\cos x + \sin x}{e^{ix}} = \frac{0}{e^{ix}} = 0$$

នាំឱ្យ $\mathbf{f(x)}$ ជាអនុគមន៍ថេរគ្រប់ $\mathbf{x}$ ។

គេបាន $f(x) = f(0) = \dfrac{\cos 0 + i\sin 0}{e^0} = 1$ ឬ $f(x) = \dfrac{\cos x + i\sin x}{e^{ix}} = 1$

ដូចនេះ $\mathbf{e^{ix} = \cos x + i\sin x}$ ។

-ស្រាយបញ្ជាក់ដោយប្រើសមីការឌីផេរ៉ង់ស្យែលលំដាប់ទីមួយ :

គេតាងអនុគមន៍ $g(x)=\cos x+i.\sin x$

គេមាន $g'(x)=-\sin x+i\cos x$

គុណអង្គទាំងពីរនឹង $i$ គេបាន $i.g'(x)=-i\sin x-\text{csox}$

គេបាន $g(x)+ig'(x)=0$ ឬ $g'(x)-i.g(x)=0$

ជាសមីការឌីផេរ៉ង់ស្យែលលំដាប់ $I$ ។

គេបានចម្លើយទូទៅនៃសមីការនេះគឺ $g(x)=k\,e^{ix}$

បើ $x=0$ នោះ $g(0)=k$ តែ $g(0)=\cos 0+i.\sin 0=1$

នោះ $k=1$ ហើយគេបាន $g(x)=e^{ix}$ ។

ដូចនេះ $e^{ix}=\cos x+i\sin x$ ។

-ស្រាយបញ្ជាក់ដោយប្រើសមីការឌីផេរ៉ង់ស្យែលលំដាប់ទីពីរ :

ជ្រើសរើសអនុគមន៍ $h(x)=e^{ix}$

គេមាន $h'(x)=i.e^{ix}$ និង $h''(x)=i^2e^{ix}=-e^{ix}$

គេបាន $h''(x)+h(x)=-e^{ix}+e^{ix}=0$ ជាសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែអូម៉ូសែន លំដាប់ទីពីរ ។

សមីការឌីផេរ៉ង់ស្យែលលីនេអ៊ែលំដាប់ពីរនេះមានចម្លើយលីនេអ៊ែឯករាជ្យលីនេអ៊ែចំនួនពីរ ដែលផ្ទៀងផ្ទាត់វាគឺ $h_1(x)=\cos x$ និង $h_2(x)=\sin x$ ។ បន្សំលីនេអ៊ែនៃចម្លើយ ចំពោះសមីការឌីផេរ៉ង់ស្យែលអូម៉ូសែន ក៏ជាចម្លើយមួយផងដែរ ។

ដូចនេះចម្លើយទូទៅនៃសមីការគឺ $h(x)=A\cos x+B\sin x$

ដែល $A$ និង $B$ ជាពីរចំនួនថេរដែលអាចរកបានតាម $h(0)=A=e^{i0}=1$

និង $h'(0)=B=ie^{i0}=i$ ព្រោះ $h'(x)=-A\sin x+B\cos x$ ។

ហេតុនេះគេបាន $h(x)=\cos x+i\sin x$ ។

ដូចនេះ $e^{ix}=\cos x+i\sin x$ ។

-ស្រាយបញ្ជាក់ដោយប្រើសេរីតៃល័រៈ

រូបមន្តស៊េរីតៃល័រចំពោះអនុគមន៍បី $e^x$ , $\cos x$ និង $\sin x$ គឺ :

$$e^x=1+\frac{x}{1!}+\frac{x^2}{2!}+\frac{x^3}{3!}+.....+\frac{x^n}{n!}+.....$$

$$\cos x=1-\frac{x^2}{2!}+\frac{x^4}{4!}-\frac{x^6}{6!}+.....+(-1)^n\frac{x^{2n}}{(2n)!}+......$$

$$\sin x=x-\frac{x^3}{3!}+\frac{x^5}{5!}-\frac{x^7}{7!}+....+(-1)^n\frac{x^{2n+1}}{(2n+1)!}+....$$

ដោយជំនួស $x$ ដោយ $ix$ ក្នុងស៊េទាំងបីនេះគេទាញបាន $e^{ix}=\cos x+i\sin x$ ។

ខ. ទម្រង់អ៊ិចស្ប៉ូណង់ស្យែល

គ្រប់ចំនួនកុំផ្លិច $z=a+i.b$ ដែល $a,b$ ជាចំនួនពិតអាចសរសេរជាទម្រង់មួយថ្មីទៀត

គឺ $z=r\,e^{i\theta}$ ដែល $r=\sqrt{a^2+b^2}$ , $\cos\theta=\frac{a}{r}$ , $\sin\theta=\frac{b}{r}$ ។

ទម្រង់ $z=r\,e^{i\theta}$ ហៅថាទម្រង់អិចស្ប៉ូណង់ស្យែលនៃ $z=a+i.b$ ។

គ. ទំនាក់ទំនងជាមួយអនុគមន៍ត្រីកោណមាត្រ :

ចំពោះគ្រប់ចំនួនពិត $\mathbf{x}$ គេមាន $\mathbf{e^{ix} = \cos x + i\sin x}$ (1)

ជំនួស $\mathbf{x}$ ដោយ $\mathbf{-x}$ គេបាន $\mathbf{e^{-ix} = \cos x - i\sin x}$ (2)

បូកសមីការ (1) និង (2) គេទាញបាន $\mathbf{e^{ix} + e^{-ix} = 2\cos x}$

គេទាញ $\mathbf{\cos x = \dfrac{e^{ix} + e^{-ix}}{2}}$ ។

ដកសមីការ (1) និង (2) គេទាញបាន $\mathbf{e^{ix} - e^{-ix} = 2i\sin x}$

គេទាញ $\mathbf{\sin x = \dfrac{e^{ix} - e^{-ix}}{2i}}$ ។

ដូចនេះ $\mathbf{\cos x = \dfrac{e^{ix} + e^{-ix}}{2}\ ;\ \sin x = \dfrac{e^{ix} - e^{-ix}}{2i}}$ ។

( រូបមន្តនេះពិតផងដែរចំពោះ $\mathbf{x}$ ជាចំនួនកុំផ្លិច )

ឃ. ទំនាក់ទំនងជាមួយអនុគមន៍អ៊ីពែបូលិកៈ

គេមាន $\mathbf{\cos x = \dfrac{e^{ix} + e^{-ix}}{2}\ ;\ \sin x = \dfrac{e^{ix} - e^{-ix}}{2i}}$

ជំនួស $\mathbf{x}$ ដោយ $\mathbf{i.x}$ គេបាន :

$$\mathbf{\cos(ix) = \frac{e^{x} + e^{-x}}{2} = \cosh x} \text{ និង } \mathbf{\sin(ix) = i\,\frac{e^{x} - e^{-x}}{2} = i\sinh x}$$

ម្យ៉ាងទៀតគេមាន $\mathbf{\cosh x = \dfrac{e^{x} + e^{-x}}{2}}$ និង $\mathbf{\sinh x = \dfrac{e^{x} - e^{-x}}{2}}$ គេបាន :

$$\mathbf{\cosh(ix) = \frac{e^{ix} + e^{-ix}}{2} = \cos x\ ,\ \sinh(ix) = \frac{e^{ix} - e^{-ix}}{2} = i\sin x} \text{ ។}$$

ឧទាហរណ៍១ : សរសេរ $z = 2 + 2i\sqrt{3}$ ជាទម្រង់អិចស្ប៉ូណង់ស្យែល ?

គេមាន $r = \sqrt{2^2 + (2\sqrt{3})^2} = 4$

គេបាន $z = 4(\frac{1}{2} + i\frac{\sqrt{3}}{2}) = 4(\cos\frac{\pi}{3} + i\sin\frac{\pi}{3}) = 4e^{i\frac{\pi}{3}}$ ។

ឧទាហរណ៍២: សរសេរ $z = 1 + e^{i\frac{\pi}{4}}$ ជារាងអិចស្ប៉ូណង់ស្យែល ?

គេមាន $z = 1 + e^{i\frac{\pi}{4}} = e^{i\frac{\pi}{8}}(e^{-i\frac{\pi}{8}} + e^{i\frac{\pi}{8}})$ ដោយ $\cos\frac{\pi}{8} = \frac{e^{i\frac{\pi}{8}} + e^{-i\frac{\pi}{8}}}{2}$

ដូចនេះ $z = 2\cos\frac{\pi}{8}.e^{i\frac{\pi}{8}}$ ។

ឧទាហរណ៍៣: គណនា $i^i$ ?

គេមាន $i = \cos\frac{\pi}{2} + i.\sin\frac{\pi}{2} = e^{i\frac{\pi}{2}}$

គេបាន $i^i = \left(e^{\frac{i\pi}{2}}\right)^i = e^{-\frac{\pi}{2}}$ ។

ឧទាហរណ៍៤: ដោះស្រាយសមីការ $\cos x = 2$ ក្នុងសំណុំកុំផ្លិច ?

តាមរូបមន្តអឺលែគេមាន $\cos x = \frac{e^{ix} + e^{-ix}}{2}$

គេបាន $\frac{e^{ix} + e^{-ix}}{2} = 2$ ឬ $e^{2ix} - 4e^{ix} + 1 = 0$ តាង $t = e^{ix}$

គេបានសមីការ $t^2 - 4t + 1 = 0$

$\Delta' = 4 - 1 = 3$ គេទាញឫស $t_1 = 2 - \sqrt{3}$ ; $t_2 = 2 + \sqrt{3}$

ចំពោះ $t = 2 - \sqrt{3}$ គេបាន $e^{ix} = 2 - \sqrt{3}$ នោះ $ix = \ln(2 - \sqrt{3})$

ឬ $x = -i\ln(2 - \sqrt{3})$ ។

ចំពោះ $t = 2 + \sqrt{3}$ គេបាន $e^{ix} = 2 + \sqrt{3}$ នោះ $ix = \ln(2 + \sqrt{3})$

ឬ $x = -i\ln(2 + \sqrt{3})$ ។

ឧទាហរណ៍៥: ដោះស្រាយសមីការ $\sin x = -3$ ក្នុងសំណុំកុំផ្លិច ?

តាមរូបមន្តអឺលែគេមាន $\sin x = \dfrac{e^{ix} - e^{-ix}}{2i}$

គេបាន $\dfrac{e^{ix} - e^{-ix}}{2i} = -3$ ឬ $e^{2ix} + 6e^{ix} - 1 = 0$ តាង $t = e^{ix}$

គេបានសមីការ $t^2 + 6t - 1 = 0$ , $\Delta' = 9 + 1 = 10$

មានឫស $t_1 = -3 + \sqrt{10}$ , $t_2 = -3 - \sqrt{10}$ ។

-ចំពោះ $t = -3 + \sqrt{10}$ គេបាន $e^{ix} = -3 + \sqrt{10}$ នោះ $x = -i\ln(-3 + \sqrt{10})$

-ចំពោះ $t = -3 - \sqrt{10} = -(3 + \sqrt{10})$

គេបាន $e^{ix} = -(3 + \sqrt{10}) = (3 + \sqrt{10})e^{i\pi} = e^{i\pi + \ln(3 + \sqrt{10})}$

គេទាញ $ix = i\pi + \ln(3 + \sqrt{10})$ ឬ $x = \pi - i\ln(3 + \sqrt{10})$ ។

ដូចនេះ $x = -i\ln(-3 + \sqrt{10})$ , $x = \pi - i\ln(3 + \sqrt{10})$ ។

## ១៣~ប្រមាណវិធីចំនួនកុំផ្លិចតាមទម្រង់អិចស្ប៉ូណង់ស្យែល

ក. ប្រមាណវិធីគុណចំនួនកុំផ្លិចតាមទម្រង់អិចស្ប៉ូណង់ស្យែល

គេមានចំនួនកុំផ្លិច $\mathbf{z = r\,e^{i\varphi}}$ និង $\mathbf{w = \rho\, e^{i\psi}}$

ដែល $\mathbf{r > 0\ ;\ \rho > 0}$ ហើយ $\varphi\ ,\ \psi$ ជាចំនួនពិត ។

គេបាន $\mathbf{z.w = r.\rho\, e^{i(\varphi+\psi)}}$ ។

ខ. ប្រមាណវិធីចែកចំនួនកុំផ្លិចតាមទម្រង់អិចស្ប៉ូណង់ស្យែល

គេមានចំនួនកុំផ្លិច $\mathbf{z = r\,e^{i\varphi}}$ និង $\mathbf{w = \rho\, e^{i\psi}}$

ដែល $\mathbf{r > 0\ ;\ \rho > 0}$ ហើយ $\varphi\ ,\ \psi$ ជាចំនួនពិត ។

គេបាន $\mathbf{\dfrac{z}{w} = \dfrac{r}{\rho} e^{i(\varphi-\psi)}}$ ។

គ. ស្វ័យគុណចំនួនកុំផ្លិចតាមទម្រង់អិចស្ប៉ូណង់ស្យែល

គេមានចំនួនកុំផ្លិច $\mathbf{z = r\,e^{i\varphi}}$ ចំពោះគ្រប់ចំនួនគត់រ៉ឡាទីហ្វ $\mathbf{n}$ គេបាន :

$$\mathbf{z^n = \left(r\,e^{i\varphi}\right)^n = r^n\, e^{in\varphi}}$$ ។

ឧទាហរណ៍ : គេឱ្យចំនួនកុំផ្លិច $\mathbf{z = 2e^{i\frac{\pi}{6}}}$ និង $\mathbf{w = 3e^{i\frac{\pi}{12}}}$ ។

គណនា $\mathbf{z.w}$ និង $\mathbf{\dfrac{z}{w}}$

គេបាន $\mathbf{z.w = 6\,e^{i(\frac{\pi}{6}+\frac{\pi}{12})} = 6e^{i\frac{\pi}{4}}}$ និង $\mathbf{\dfrac{z}{w} = \dfrac{2}{3} e^{i(\frac{\pi}{6}-\frac{\pi}{12})} = \dfrac{2}{3} e^{i\frac{\pi}{12}}}$

## ១៤-អនុវត្តន៍ចំនួនកុំផ្លិចក្នុងត្រីកោណមាត្រ

ក. រូបមន្តមុំឌុប

ចំពោះគ្រប់ចំនួនពិត $\mathbf{x}$ គេមាន $\cos x=\frac{e^{ix}+e^{-ix}}{2}$ ; $\sin x=\frac{e^{ix}-e^{-ix}}{2i}$

គេបាន $\cos^2 x=\left(\frac{e^{ix}+e^{-ix}}{2}\right)^2=\frac{e^{2ix}+e^{-2ix}+2}{4}$

$$\cos^2 x=\frac{1}{2}.\frac{e^{2ix}+e^{-i2x}}{2}+\frac{1}{2}=\frac{1}{2}\cos 2x+\frac{1}{2}$$

គេទាញ $\cos 2x=2\cos^2 x-1$ ។

ហើយ $\sin 2x=\frac{e^{2ix}-e^{-2ix}}{2i}=2.\frac{e^{ix}-e^{-ix}}{2i}.\frac{e^{ix}+e^{-ix}}{2}$

ដូចនេះ $\sin 2x=2\sin x\cos x$ ។

ខ. រូបមន្តមុំទ្រីប

គេមាន $\cos^3 x=\left(\frac{e^{ix}+e^{-ix}}{2}\right)^3$

$$=\frac{e^{3ix}+e^{-3ix}+3(e^{ix}+e^{-ix})}{8}$$

$$=\frac{2\cos 3x+6\cos x}{8}=\frac{\cos 3x+3\cos x}{4}$$

គេទាញបាន $\cos 3x=4\cos^3 x-3\cos x$ ។

ហើយ $\sin^3 x = \left(\frac{e^{ix} - e^{-ix}}{2i}\right)^3$

$$= \frac{(e^{3ix} - e^{-3ix}) - 3(e^{ix} - e^{-ix})}{-8i}$$

$$= \frac{2i\sin 3x - 6i\sin x}{-8i}$$

$$= \frac{\sin 3x - 3\sin x}{-4}$$

គេទាញបាន $\sin 3x = 3\sin x - 4\sin^3 x$ ។

គ. រូបមន្តផលបូក និង ផលដកនៃមុំពីរ

គេមាន $e^{i(a+b)} = e^{ia}.e^{ib}$ គ្រប់ចំនួនពិត $a$ និង $b$

ដោយ $e^{ia}.e^{ib} = (\cos a + i\sin a)(\cos b + i\sin b)$

$$e^{ia}e^{ib} = (\cos a\cos b - \sin a\sin b) + i(\sin a\cos b + \sin b\cos a)$$

ហើយ $e^{i(a+b)} = \cos(a+b) + i\sin(a+b)$

ដូចនេះ $\cos(a+b) = \cos a\cos b - \sin a\sin b$

និង $\sin(a+b) = \sin a\cos b + \sin b\cos a$ ។

ម្យ៉ាងទៀត $e^{i(a-b)} = e^{ia}.e^{-ib}$ គ្រប់ចំនួនពិត $a$ និង $b$

ដោយ $e^{ia}.e^{-ib} = (\cos a + i\sin a)(\cos b - i\sin b)$

$$e^{ia}e^{-ib} = (\cos a\cos b + \sin a\sin b) + i(\sin a\cos b - \sin b\cos a)$$

ហើយ $e^{i(a-b)} = \cos(a-b) + i\sin(a-b)$

ដូចនេះ $\cos(a-b)=\cos a\cos b+\sin a\sin b$

និង $\sin(a-b)=\sin a\cos b-\sin b\cos a$ ។

ឃ. រូបមន្តបំលែងពីផលគុណទៅផលបូក

$$\cos a\cos b=\frac{e^{ia}+e^{-ia}}{2}.\frac{e^{ib}+e^{-ib}}{2}$$

$$=\frac{e^{i(a+b)}+e^{i(a-b)}+e^{-i(a-b)}+e^{-i(a+b)}}{4}$$

$$=\frac{1}{2}\left[\frac{e^{i(a+b)}+e^{-i(a+b)}}{2}+\frac{e^{i(a-b)}+e^{-i(a-b)}}{2}\right]$$

$$=\frac{1}{2}\left[\cos(a+b)+\cos(a-b)\right]$$

ដូចនេះ $\cos a\cos b=\frac{1}{2}\left[\cos(a+b)+\cos(a-b)\right]$

$$\sin a\sin b=\frac{e^{ia}-e^{-ia}}{2i}.\frac{e^{ib}-e^{-ib}}{2i}$$

$$=\frac{e^{i(a+b)}-e^{i(a-b)}-e^{-i(a-b)}+e^{-i(a+b)}}{4i^2}$$

$$=-\frac{1}{2}\left[\frac{e^{i(a+b)}+e^{-i(a+b)}}{2}-\frac{e^{i(a-b)}+e^{-i(a-b)}}{2}\right]$$

$$=-\frac{1}{2}\left[\cos(a+b)-\cos(a-b)\right]$$

ដូចនេះ $\sin a\sin b=\frac{1}{2}\left[\cos(a-b)+\cos(a+b)\right]$

## ១៥-អនុវត្តន៍ចំនួនកុំផ្លិចក្នុងស្វីតចំនួនពិត

ចំពោះស្វ៊ីតនៃចំនួនពិត $(a_n)$ ដែលផ្ទៀងផ្ទាត់ទំនាក់ទំនងកំណើន :

$a_{n+2}+pa_{n+1}+qa_n=0$ ដែល $p,q$ ជាចំនួនពិត

សមីការសម្គាល់របស់ស្វ៊ីតនេះគឺ $z^2+pz+q=0$

ក្នុងករណី $\Delta=p^2-4q<0$ សមីការមានឫសពីរជាចំនួនកុំផ្លិចឆ្លាស់គ្នា

គឺ $z_1$ និង $z_2$ ។ ក្នុងករណីនេះដើម្បីគណនា $a_n$ គេត្រូវអនុវត្តន៍ដូចតទៅ :

តាងស្វ៊ីតជំនួយ $z_n=a_{n+1}-z_1a_n$ រួចស្រាយថា $(z_n)$ ជាស្វ៊ីតធរណីមាត្រនៃចំនួនកុំផ្លិចមួយ ។

គណនា $z_n$ រួចទាញរក $a_n$ ។

ឧទាហរណ៍ គេមានស្វ៊ីតនៃចំនួនពិត $(a_n)$ កំណត់ដោយ :

$a_0=0$ , $a_1=1$ និង $a_{n+2}=a_{n+1}-a_n$

ចូរគណនា $a_n$ ជាអនុគមន៍នៃ $n$

## ១៦-អនុវត្តន៍ចំនួនកុំផ្លិចក្នុងធរណីមាត្រ

ក. ចម្ងាយរវាងពីរចំនុច

ខ. ចំនុចចែកអង្កត់តាមផលធៀបមួយ

គ. ផលធៀបជ្រុង និង មុំនៃត្រីកោណក្នុងប្លង់

ឃ. សំណុំចំណុចក្នុងប្លង់កុំផ្លិច